# របាយការណ៍សិក្ខាសាលាស្តីពី
# «ការឆ្លុះបញ្ចាំង និងការឆ្លើយតបទៅនឹងអនុសាសន៍ណែនាំរបស់ក្រុមអធិការកិច្ច»



សហការរៀបចំដោយ៖

ឧបត្ថម្ភដោយ៖

water.org

# មាតិកា


១. **សេចក្តីផ្តើម** ........ 1

២. **សកម្មភាព និងលទ្ធផលនៃសិក្ខាសាលា** ........ 1

២.១. កម្មវិធីបើកសិក្ខាសាលា ........ 1

ក. សុន្ទរកថាស្វាគមន៍ ........ 1

ខ. សុន្ទរកថាបើកសិក្ខាសាលា ........ 2

២.២ បទបង្ហាញស្តីពីលទ្ធផលវាយតម្លៃ និងចំណុចសំខាន់ៗ ........ 4

២.៣ បទបង្ហាញអំពីលទ្ធផលនៃការស្ទង់មតិរបស់ប្រតិបត្តិករ ........ 5

២.៤ កិច្ចពិភាក្សាឆ្លុះបញ្ចាំងរបស់ប្រតិបត្តិករ ........ 5

២.៥ កម្មវិធីបិទសិក្ខាសាលា ........ 7

៣. **សេចក្តីសន្និដ្ឋាន** ........ 7

៤. **ឧបសម្ព័ន្ធ** ........ 8

## ១. សេចក្តីផ្តើម

ថ្ងៃអង្គារ ១៤កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៦ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានសហការជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ឧ.វ.ប.ន.) រៀបចំសិក្ខាសាលាស្តីពី**«ការឆ្លុះបញ្ចាំង និងការឆ្លើយតបទៅនឹងអនុសាសន៍ណែនាំរបស់ក្រុមអធិការកិច្ច»** ក្រោមការឧបត្ថម្ភពីអង្គការ Water.org។ សិក្ខាសាលានេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុំ សុថា រដ្ឋលេខាធិការ** និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ក្រសួង ឧ.វ.ប.ន. ជាប្រធានគណៈអធិបតី **លោក លឹម មិញ នាយកប្រតិបត្តិ** សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា និង**លោកស្រី អយ សត្យា អ្នកដឹកនាំផលប័ត្រ** នៃអង្គការ Water.org។ គោលបំណងនៃសិក្ខាសាលា៖

១. កំណត់ចំណុចដែលប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ត្រូវកែលម្អ ដោយផ្អែកលើលទ្ធផលក្នុងរបាយការណ៍។

២. ពិភាក្សាអំពីវិធីសាស្ត្រ និងផែនការដែលប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននឹងអនុវត្ត ដើម្បីកែលម្អ ដោយផ្អែកលើលទ្ធផល និងអនុសាសន៍ក្នុងរបាយការណ៍។

៣. ពិភាក្សាអំពីការគាំទ្ររបស់ក្រសួង ឧ.វ.ប.ន. និង/ឬសមាគម ដៃគូអភិវឌ្ឍន៍ក្នុងការជួយប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនអនុវត្តសកម្មភាពកែលម្អទាំងនោះ។

សិក្ខាសាលានេះមានសមាសភាពអញ្ជើញចូលរួមពីក្រសួង ឧ.វ.ប.ន. ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន អង្គការ Water.org និងសមាគម សរុបចំនួន **៧០ នាក់ (ស្រី ១៤ នាក់)** ក្នុងនោះមានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន **៥៤ ស្ថានីយ**។



*រូបភាពទី ១៖ រូបថតអនុស្សាវរីយ៍ជាមួយគណៈអធិបតី*

## ២. សកម្មភាព និងលទ្ធផលនៃសិក្ខាសាលា

### ២.១. កម្មវិធីបើកសិក្ខាសាលា

#### ក. សុន្ទរកថាស្វាគមន៍

ក្នុងឱកាសបើកសិក្ខាសាលា **លោក លឹម មិញ នាយកប្រតិបត្តិ** សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានសម្តែងការស្វាគមន៍ និងថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំក្រសួង ឧ.វ.ប.ន. អង្គការ Water.org និងភ្ញៀវកិត្តិយសទាំងអស់ ដែលបានចូលរួម និងគាំទ្រការរៀបចំសិក្ខាសាលានេះ។

លោកនាយកប្រតិបត្តិ បានបញ្ជាក់ថា សិក្ខាសាលានេះមានគោលបំណងឆ្លុះបញ្ចាំងលទ្ធផលនៃការចុះអធិការកិច្ច ពិភាក្សាអំពីចំណុចដែលត្រូវកែលម្អ និងរៀបចំផែនការសកម្មភាព ដើម្បីឆ្លើយតបទៅនឹងអនុសាសន៍របស់ក្រសួងព្រមទាំងពង្រឹងកិច្ចសហការរវាងក្រសួង សមាគម ដៃគូអភិវឌ្ឍន៍ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន។




*រូបភាពទី ២៖ សុន្ទរកថាស្វាគមន៍របស់ **លោក លឹម មិញ** នាយកប្រតិបត្តិ*

ទន្ទឹមនឹងនេះលោកនាយកប្រតិបត្តិបានលើកឡើងថា លទ្ធផលអធិការកិច្ចគួរត្រូវបានចាត់ទុកជាឱកាសសម្រាប់ការកែលម្អការគ្រប់គ្រង និងការពង្រឹងសមត្ថភាពប្រតិបត្តិការ ដើម្បីលើកកម្ពស់គុណភាពសេវាផ្គត់ផ្គង់ទឹកស្អាត កាត់បន្ថយទឹកគ្មានចំណូល (NRW) និងពង្រឹងនិរន្តរភាពនៃអាជីវកម្ម។ ជាមួយគ្នានេះ សមាគមបានបញ្ជាក់ពីការបន្តគាំទ្រសមាជិកតាមរយៈការបណ្តុះបណ្តាល ការផ្តល់ប្រឹក្សាបច្ចេកទេស និងការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ ព្រមទាំងអំពាវនាវឱ្យប្រតិបត្តិករទាំងអស់ចូលរួមយ៉ាងសកម្មក្នុងការពិភាក្សា ចែករំលែកបទពិសោធន៍ និងរៀបចំផែនការកែលម្អដែលអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព។

## ខ. សុន្ទរកថាបើកសិក្ខាសាលា




*រូបភាពទី ៣៖ សុន្ទរកថារបស់ **ឯកឧត្តម អ៊ុំ សុថា***

**ឯកឧត្តម អ៊ុំ សុថា រដ្ឋលេខាធិការ** និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ក្រសួង ឧ.វ.ប.ន. បានផ្តល់កិត្តិយសអញ្ជើញថ្លែងសុន្ទរកថា ដោយបានកោតសរសើរចំពោះសមាគម CWA និងអង្គការ Water.org ក្នុងការសហការរៀបចំសិក្ខាសាលានេះ ដើម្បីឆ្លុះបញ្ចាំងលទ្ធផលនៃការចុះអធិការកិច្ច ពិភាក្សាអំពីបញ្ហាប្រឈម និងកំណត់វិធានការកែលម្អការអនុវត្តរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន។

**ឯកឧត្តម** បានគូសបញ្ជាក់ថា ដើម្បីឱ្យសេវាសាធារណៈក្នុងវិស័យទឹកស្អាត ឆ្លើយតបទៅនឹងគោលបំណងខាងលើនេះ, ការប្រតិបត្តិឱ្យបានខ្ជាប់ខ្ជួន ហ្មត់ចត់ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចំពោះបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ក៏ដូចជាលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ, ជាពិសេស ច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត គឺជាការចាំបាច់បំផុត និងជាកាតព្វកិច្ចរបស់អ្នកធ្វើការងារ ឬប្រកបធុរកិច្ចក្នុងវិស័យទឹកស្អាត។ ក្នុងន័យនេះ ក្រសួងឧ.វ.ប.ន. បានបន្តពង្រឹងការងារអធិការកិច្ច និងការត្រួតពិនិត្យ វាយតម្លៃជាប្រចាំ ដើម្បីធានាថា ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតអនុវត្តបានស្របតាមច្បាប់ បទប្បញ្ញត្តិ និងស្តង់ដាបច្ចេកទេស។ ការចុះអធិការកិច្ច មិនមែនជាការស្វែងរកកំហុស ឬការដាក់ទណ្ឌកម្មនោះទេ, ប៉ុន្តែជាយន្តការសម្រាប់ការកែលម្អ ការពង្រឹងអភិបាលកិច្ច និងការអភិវឌ្ឍសមត្ថភាពរបស់ប្រតិបត្តិករ ដើម្បីឱ្យការផ្គត់ផ្គង់ទឹកស្អាតកាន់តែមានគុណភាព សុវត្ថិភាព និងអាចឆ្លើយតបទៅនឹងតម្រូវការ

របស់ប្រជាពលរដ្ឋបានកាន់តែប្រសើរ។ និយាយបែបសាមញ្ញ គឺយើងត្រូវតែធ្វើការឆែកមើលសុខភាពរបស់យើងជារឿយៗ និងត្រូវតែមានការថែទាំ ព្យាបាល ជួសជុល ឬវះកាត់។

ខ្ញុំសូមយកឱកាសនេះ ញ្ញើចយកលទ្ធផលនៃការចុះអធិការកិច្ចកន្លងទៅមកជម្រាបជូនថា ក្នុងគោលដៅ ៤៤១ ប្រតិបត្តិករទឹកស្អាតឯកជន, បានអនុវត្តរួចរាល់ ៣៤២ ប្រតិបត្តិករ នៃ ៣៦០ ប្រតិបត្តិករ ដែលស្ថិតក្នុងដំហានបេសកកម្មរបស់ក្រុមអធិការកិច្ចដែលមាន ៤ ក្រុម ថែមទាំងមានការជួយគាំទ្រក្នុងក្របខណ្ឌការងាររបស់អង្គការ UNICEF ដោយឡែកផងដែរ។ របាយការណ៍លទ្ធផលចំនួន ២៩២ ត្រូវបានគោរពរាយការណ៍ជូនឯកឧត្តមរដ្ឋមន្ត្រី និងទទួលបានអនុសាសន៍/គោលការណ៍រួចរាល់ផងដែរ។ ផ្អែកលើរបាយការណ៍នេះ ក្រសួងក៏បានដាក់ចេញជាលិខិតវិធានការណែនាំឱ្យកែលម្អ/ដាក់លក្ខខណ្ឌកំហិតឱ្យអនុវត្តចំនួន ២៨៨ លិខិត និងក៏មាននីតិវិធីផ្សេងទៀត ពាក់ព័ន្ធនឹងវិធានការចុងក្រោយ គឺការដកហូតអាជ្ញាបណ្ណមួយចំនួនវិញ, ការកាត់ផ្ទៀលតំបន់សេវាក្នុងអាជ្ញាបណ្ណ និងការបញ្ចប់នីតិវិធីផ្តល់អាជ្ញាបណ្ណជាដើម។

តាមការវាយតម្លៃជារួម ចំណាត់ថ្នាក់ល្អ មានតែ ៦%, ក្រៅពីនោះ ល្អបង្គួរមាន ៤១%, មធ្យម ២៧%, ខ្សោយ ១៣% (៣៨ ប្រតិបត្តិករ), មិនអនុលោម ៩% (២៦ ប្រតិបត្តិករ) [មិនអនុលោម សំដៅដល់ប្រតិបត្តិករដែលមិនបានអនុវត្តតាមលក្ខខណ្ឌប្រកាសអនុញ្ញាត ដូចជាមិនបានសាងសង់, សាងសង់យឺតជាងផែនការ ហើយមិនបានផ្គត់ផ្គង់ទឹកជូនប្រជាពលរដ្ឋទាន់ពេល និងមិនសហការអនុវត្ត]។ ចំពោះព័ត៌មាន និងលទ្ធផលលម្អិត ខ្ញុំសូមប្រគល់ជូនលោកអនុប្រធាននាយកដ្ឋានទាំង ២ រូប តំណាងអគ្គនាយកដ្ឋានទឹកស្អាតធ្វើបទបង្ហាញជូនអង្គសិក្ខាសាលា។

ពិតមែនហើយ មិនមែនអ្វីៗសុទ្ធតែសម្រេចបានល្អឥតខ្ចោះនោះទេ, ប៉ុន្តែ សំខាន់គឺយើងធ្វើឱ្យប្រជាពលរដ្ឋយើង អតិថិជនយើង មើលឃើញ និងជឿទុកចិត្តលើសមត្ថភាពរបស់យើងជាប្រតិបត្តិករ ហើយគាំទ្រយើង និងចាត់ទុកប្រតិបត្តិករជាដៃគូមិនអាចខ្វះបានរបស់ពួកគាត់។

បើយើងមានឆន្ទៈ និងការប្តេជ្ញាចិត្តមោះមុត, ថ្ងៃនេះ យើងសម្រេចបានកម្រិតប៉ុណ្ណឹង ឬកម្រិតមធ្យមពិតមែន, ប៉ុន្តែ ថ្ងៃក្រោយ ខែក្រោយ ឆ្នាំក្រោយ យើងនឹងមានវឌ្ឍនភាពថ្មី ល្អប្រសើរ ដែលធ្វើឱ្យរដ្ឋកាន់តែមានជំនឿទុកចិត្ត ហើយគាំទ្រ ការពារយើងបន្ថែមទៀត។ ផ្ទុយទៅវិញ បើនៅទ្រឹង ប្រាកដណាស់ បុគ្គលជាប្រតិបត្តិករនោះនឹងទទួលរងការដាក់កំហិតជាវិធានការដាក់លាក់តាមផ្លូវច្បាប់ជាមិនខាន។ **ឯកឧត្តម** ក៏បានបង្ហាញលទ្ធផលសង្ខេបនៃការចុះអធិការកិច្ច និងជំរុញឱ្យប្រតិបត្តិករអនុវត្តអនុសាសន៍របស់ក្រុមអធិការកិច្ចរបស់ក្រសួងឱ្យបានម៉ឺងម៉ាត់ ដើម្បីបង្កើនការអនុលោមតាមច្បាប់ និងស្តង់ដាបច្ចេកទេស។

ជាមួយគ្នានេះ **ឯកឧត្តម** បានលើកទឹកចិត្តឱ្យប្រតិបត្តិករបន្តធ្វើទំនើបកម្មវិស័យទឹកស្អាត តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឆ្លាតវៃ ការគ្រប់គ្រងទិន្នន័យឌីជីថល ការកាត់បន្ថយទឹកគ្មានចំណូល (NRW) ការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព និងការរៀបចំផែនការវិនិយោគរយៈពេលវែង។ ទន្ទឹមនឹងនេះ ក្រសួងនឹងបន្តសហការជាមួយសមាគម អង្គការ Water.org និងដៃគូអភិវឌ្ឍន៍ ដើម្បីពង្រឹងសមត្ថភាព ផ្ទេរបច្ចេកវិទ្យា និងគាំទ្រការវិនិយោគក្នុងវិស័យទឹកស្អាត។ **ឯកឧត្តម** ក៏បានអំពាវនាវឱ្យអ្នកចូលរួមទាំងអស់ចូលរួមយ៉ាងសកម្មក្នុងការពិភាក្សា ចែករំលែកបទពិសោធន៍ និងបញ្ហាដែលបានជួបប្រទះ ឬអនុសាសន៍របស់ក្រុមការងារអធិការកិច្ចបង្កើតទៅជាទស្សនថ្មី គំនិតថ្មី វិធានការថ្មីៗជាគន្លឹះ ដើម្បីជម្រះកត្តាអសកម្ម កត្តាមិនមានអនុលោមភាព ប្រែក្លាយទៅជាកត្តាសកម្ម និងមានអនុលោមភាព ហើយធានាបានវត្ថុបំណងរបស់យើងគឺ៖ (១)ការបម្រើសេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងភាពជឿជាក់ (២)ការធានាបានសុខភាពហិរញ្ញវត្ថុ និងនិរន្តរភាពនៃប្រតិបត្តិការអាជីវកម្មរយៈពេលវែង (៣)ការឆ្លើយតបទៅនឹងគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋា

ភិបាលក្នុងវិស័យទឹកស្អាត។ ដូច្នេះរួមគ្នាលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងនិរន្តរភាពនៃសេវាផ្គត់ផ្គង់ទឹកស្អាត ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

## ២.២ បទបង្ហាញស្ដីពីលទ្ធផលវាយតម្លៃ និងចំណុចសំខាន់ៗ

**លោក ចាន់ ពុទ្ធារក្ស អនុប្រធាន** នាយកដ្ឋានបញ្ញត្តកម្មទឹកស្អាតនៃអគ្គនាយកដ្ឋានទឹកស្អាត បានធ្វើបទបង្ហាញស្ដីពី**«លទ្ធផលនៃការវាយតម្លៃរបស់ក្រុមការងារចុះពិនិត្យ និងវាយតម្លៃស្ថានភាពជាក់ស្ដែងរបស់ប្រតិបត្តិករផ្ដល់សេវាផ្គង់ផ្គង់ទឹកស្អាតឯកជន និងចំណុចសំខាន់ៗដែលបានរកឃើញ»**។



*រូបភាពទី ៤៖ បទបង្ហាញរបស់ **លោក ចាន់ ពុទ្ធារក្ស***

បទបង្ហាញបានផ្ដោតលើមាតិកាសំខាន់ៗ ដូចជា៖ ១).គោលបំណង ២).មូលដ្ឋានច្បាប់ និងឯកសារគតិយុត្តិពាក់ព័ន្ធ ៣).ក្រុមការងារចុះពិនិត្យ និងវាយតម្លៃស្ថានភាពជាក់ស្ដែងរបស់ប្រតិបត្តិករផ្ដល់សេវាផ្គង់ផ្គង់ទឹកស្អាតឯកជន ៤).វិធីសាស្ត្រ និងសូចនាករនៃការវាយតម្លៃ ៥).វឌ្ឍនភាពសរុបនៃការចុះធ្វើត្រួតពិនិត្យ ៦).បញ្ហាប្រឈមគន្លឹះ ៧).លទ្ធផលវិភាគលើផែនការវិនិយោគ ៨).តួនាទីរបស់មន្ទីរ ឧ.វ.ប.ន. រាជធានីខេត្ត ៩).អនុសាសន៍ និងកិច្ចការគាំទ្ររបស់ក្រសួង និង ១០).ក្របខណ្ឌច្បាប់ស្ដីពីការគ្រប់គ្រងទឹកស្អាត (ទណ្ឌកម្មរដ្ឋបាល ការពិន័យអន្តរការណ៍ និងទណ្ឌកម្មព្រហ្មទណ្ឌ)។






## ២.៣ បទបង្ហាញអំពីលទ្ធផលនៃការស្ទង់មតិរបស់ប្រតិបត្តិករ

**លោក លឹម មិញ នាយកប្រតិបត្តិសមាគម** បានធ្វើបទបង្ហាញអំពី លទ្ធផលនៃការស្ទង់មតិរបស់ប្រតិបត្តិករ លើការទទួលបានលិខិតជូនដំណឹងស្តីពី«**វិធានការត្រូវអនុវត្តក្នុងការកែតម្រូវកំហុស និងកែលម្អចំណុចខ្វះខាតពាក់ព័ន្ធនឹងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត**»។

ប្រតិបត្តិករចំនួន **៥៥ ស្ថានីយ** បានសំណូមពរ ឬយោបល់ផ្សេងៗ ដូចខាងក្រោម៖

- **១៨ ស្ថានីយ (៣២.៧%)** មិនមានយោបល់ ឬសំណូមពរបន្ថែម។
- **១១ ស្ថានីយ (២០.០%)** ស្នើសុំការគាំទ្រផ្នែក បច្ចេកទេស និងការបណ្តុះបណ្តាល ដូចជា ការគ្រប់គ្រងអាជីវកម្ម ការផលិត ទឹក ការសរសេររបាយការណ៍ហិរញ្ញវត្ថុ និងការពង្រឹងសមត្ថភាពបុគ្គលិក។
- **១០ ស្ថានីយ (១៨.២%)** ស្នើសុំឱ្យ ក្រសួង និងសមាគម ជួយសម្របសម្រួលគោលនយោបាយ និងដោះស្រាយបញ្ហាប្រឈម ដូចជា តម្លៃលក់ទឹក ថ្លៃថែទាំនាឡិកា ការរំលោភដែនអាជ្ញាបណ្ណ និងការពន្យារពេលអនុវត្តអនុសាសន៍មួយចំនួន។
- **៨ ស្ថានីយ (១៤.៥%)** ស្នើសុំឱ្យមាន ការផ្សព្វផ្សាយ និងបង្កើនការយល់ដឹង ដល់ប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋានអំពី សារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាត និងច្បាប់ពាក់ព័ន្ធ។
- **៨ ស្ថានីយ (១៤.៥%)** ស្នើសុំការគាំទ្រលើ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដូចជា ការពង្រីកបណ្តាញទឹក ការសហការពេលសាងសង់ផ្លូវ និងការភ្ជាប់អតិថិជនថ្មី។
- **៧ ស្ថានីយ (១២.៧%)** ស្នើសុំការគាំទ្រផ្នែក ហិរញ្ញវត្ថុ និងសំណង រួមទាំងសំណងការខូចខាតបំពង់ទឹក និងការគាំទ្រដើមទុន។
- **៣ ស្ថានីយ (៥.៥%)** ស្នើសុំឱ្យមានដំណោះស្រាយលើ បញ្ហាប្រភពទឹកធៅ។
- **៣ ស្ថានីយ (៥.៥%)** ស្នើសុំឱ្យក្រសួងបន្ត ការចុះអធិការកិច្ច ការត្រួតពិនិត្យ និងផ្តល់អនុសាសន៍ ដើម្បីជួយកែលម្អការអនុវត្ត។

## ២.៤ កិច្ចពិភាក្សាឆ្លុះបញ្ចាំងរបស់ប្រតិបត្តិករ

**លោក លឹម មិញ នាយកប្រតិបត្តិសមាគម** បានសម្របសម្រួលកិច្ចពិភាក្សាឆ្លុះបញ្ចាំងរបស់ប្រតិបត្តិករតាមខេត្ត ដូចជា៖ ១).កំពង់ចាម & ត្បូងឃ្មុំ ២).កំពង់ឆ្នាំង និងកំពង់ធំ ៣).បាត់ដំបង ៤).ព្រៃវែង ៥).ក្រចេះ និងកំពង់ស្ពឺ ៦).បន្ទាយមានជ័យ និងសៀមរាប ៧).កណ្តាល និង ៨).តាកែវ។ សំណួរឆ្លុះបញ្ចាំងរួមមាន៖

១. យោងតាមរបាយការណ៍អធិការកិច្ចរបស់ក្រសួង ឧ.វ.ប.ន. តើអ្វីខ្លះជាចំណុចអាទិភាពសម្រាប់ការកែលម្អស្ថានីយរបស់អ្នក?
២. តើចំណុចអាទិភាពសម្រាប់កែលម្អណាខ្លះដែលស្ថានីយរបស់អ្នកអាចអនុវត្តបាន?
៣. តើចំណុចអាទិភាពណាខ្លះដែលមិនអាចអនុវត្តបាន? ហេតុអ្វី?

ជាសេចក្តីសង្ខេបលទ្ធផលនៃកិច្ចពិភាក្សាមានអនុសាសន៍មួយចំនួនដែលប្រតិបត្តិករខ្លះមិនអាចអនុវត្តបាន ឬមានការលំបាកក្នុងការអនុវត្ត រួមមាន៖

**១. ការពង្រីកតំបន់សេវាកម្ម និងបណ្តាញចែកចាយទឹក**

- ស្នើសុំក្រសួងពន្លឿនការអនុម័តសំណើពង្រីកតំបន់សេវាកម្ម ដែលប្រតិបត្តិករបានដាក់ជូនរួចហើយ។
- ស្នើសុំពន្យារពេលអនុវត្តការពង្រីកបណ្តាញចែកចាយទឹកឱ្យគ្របដណ្តប់ពេញផ្ទៃសេវាកម្ម ដោយសាររយៈពេលកំណត់បច្ចុប្បន្នមិនគ្រប់គ្រាន់។

**២. ការពង្រឹងការគ្រប់គ្រងប្រតិបត្តិការ**

- ប្រតិបត្តិករជួបការលំបាកក្នុងការគ្រប់គ្រងទិន្នន័យប្រតិបត្តិការ និងអាជីវកម្ម ដោយសារកង្វះធនធានមនុស្ស និងសមត្ថភាពបច្ចេកទេស។

**៣. ការធានាប្រភពទឹក និងហេដ្ឋារចនាសម្ព័ន្ធ**

- ប្រឈមនឹងការខ្វះប្រភពទឹកឆៅ ជាពិសេសស្ថានីយដែលពឹងផ្អែកលើទឹកភ្លៀង ដូច្នេះត្រូវការវិធានការការពារ និងអភិរក្សប្រភពទឹក។
- ត្រូវការវិនិយោគលើឧបករណ៍គាំទ្រ ដូចជា ម៉ាស៊ីនភ្លើងបម្រុង ដើម្បីធានានិរន្តរភាពនៃការផ្គត់ផ្គង់ទឹក។

**៤. ការអនុលោមតាមអាជ្ញាបណ្ណ**

- ប្រតិបត្តិករមួយចំនួននៅផ្គត់ផ្គង់ទឹកលើសពីតំបន់ដែលបានអនុញ្ញាតក្នុងអាជ្ញាបណ្ណ។
- ប្រតិបត្តិករមួយចំនួនមិនទាន់មានការកំណត់ថ្លៃថែទាំនាឡិកាទឹកក្នុងអាជ្ញាបណ្ណ ហើយកំពុងស្នើសុំការអនុម័តពីក្រសួង។

**៥. ការធានាប្រភពទឹកផ្គត់ផ្គង់**

- ស្នើលើកទឹកចិត្ត និងសម្របសម្រួលការទិញទឹកដុំពីរោងចក្រទឹក ក្នុងតំបន់ដែលមានលទ្ធភាព ដើម្បីបង្កើនស្ថិរភាពនៃការផ្គត់ផ្គង់ទឹកស្អាត។




*រូបភាពទី ៥៖ កិច្ចពិភាក្សាក្រុមរបស់ប្រតិបត្តិករតាមខេត្តនីមួយៗ*

ដើម្បីចូលរួមដោះស្រាយបញ្ហាប្រឈមរបស់ប្រតិបត្តិករក្នុងការអនុវត្តអនុសាសន៍របស់ក្រសួង សមាគមនឹងធ្វើការសហការជាមួយអគ្គនាយកដ្ឋានទឹកស្អាតក្នុងការកំណត់សម្គាល់របស់ប្រតិបត្តិករដែលស្ថិតនៅក្នុងកម្រិតអនុលោមភាពពី **«ល្អ» «ល្អបង្គួរ» «មធ្យម» «ខ្សោយ» «មិនអនុលោម»** និង**«មិនទាន់សាងសង់»**។ ជាងនេះទៀត សមាគមបានណែនាំអំពីគំរូផែនការសកម្មភាពសម្រាប់ការអនុវត្តអនុសាសន៍របស់ក្រសួង ឧ.វ.ប.ន.។

## ២.៥ កម្មវិធីបិទសិក្ខាសាលា

**ឯកឧត្តម អ៊ុំ សុថា រដ្ឋលេខាធិការ** ក្រសួង ឧ.វ.ប.ន. បានអញ្ជើញថ្លែងសុន្ទរកថា បិទសិក្ខាសាលា ដោយបានផ្តល់អនុសាសន៍ផ្តាំផ្ញើជូនប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតទាំងអស់ដូចខាងក្រោម៖

- សូមបន្តសហការល្អជាមួយអាជ្ញាធរមូលដ្ឋាន និងពន្យល់ពួកគាត់បន្ថែមទៀតអំពីច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាតឱ្យបានយល់ច្បាស់ សារៈសំខាន់នៃសេវាផ្គត់ផ្គង់ទឹកស្អាត ដែលជាសេវាសាធារណៈរបស់រដ្ឋ និងដើម្បីផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ប្រជាជនក្នុងមូលដ្ឋាន ទោះបីជាផ្នែកឯកជនកំពុងអនុវត្តកិច្ចការនេះក៏ដោយ ក៏ជាការអនុវត្តការកិច្ចក្នុងនាមរដ្ឋដែរ និងស្នើសុំការគាំទ្រពីពួកគាត់។
- ដើម្បីកាត់បន្ថយបញ្ហាប្រឈមនឹងការខូចខាតបណ្តាញទឹកស្អាត, ការដោះស្រាយប្រភពទឹក, សូមប្រើប្រាស់សៀវភៅច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត និងបង្ហាញជូនអាជ្ញាធរមូលដ្ឋាន និងភាគីពាក់ព័ន្ធគ្រប់កម្មវិធីតាមដែលអាចធ្វើទៅបាន។
- សូមបន្តរួមគ្នាដោះស្រាយបញ្ហាប្រឈមនានាក្នុងវិស័យដោយចាប់ផ្តើមពីថ្នាក់មូលដ្ឋានឡើងមក ដោយភាពម្ចាស់ការ និងភាពជាអ្នកដឹកនាំ ឬអ្នកគ្រប់គ្រង។
- សូមយកចំណុចដែលបានជជែកពិភាក្សានាថ្ងៃនេះទៅអនុវត្តបន្ថែមដើម្បីអភិវឌ្ឍវិស័យទឹកស្អាតឱ្យកាន់តែរីកចម្រើន និងសម្រេចតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។
- យោងតាមអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៦ ស្តីពី លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ដែលទើបត្រូវបានដាក់ឱ្យអនុវត្ត គឺតម្រូវឱ្យអ្នកកាន់អាជ្ញាបណ្ណជានីតិបុគ្គល។ ហេតុដូច្នេះ ជាការចាំបាច់ដែលសាមីប្រតិបត្តិករត្រូវពង្រឹងសមត្ថភាព ទាំងការគ្រប់គ្រងដំណើរការផលិតកម្ម ទាំងការគ្រប់គ្រងការងារហិរញ្ញវត្ថុ និងកិច្ចបញ្ជីការនានាឱ្យបានល្អហ្មត់ចត់។
- សូមប្រតិបត្តិករទាំងអស់ចូលរួមជាមួយសមាគមដើម្បីទទួលបានព័ត៌មាន ដើម្បីមានសំឡេងសមូហភាពក្នុងការទទួលបានការផ្សព្វផ្សាយ ការបណ្តុះបណ្តាល ការធ្វើអន្តរាគមន៍ផ្សេងៗ ឬការដោះស្រាយបញ្ហាប្រឈម/សំណូមពរងាយស្រួល ល្អជាងនៅក្រៅសមូហភាពសមាគម ដើម្បីចូលរួមអភិវឌ្ឍវិស័យទឹកស្អាត។

**ឯកឧត្តមប្រធានគណៈអធិបតី** បានអំណរគុណចំពោះមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានទឹកស្អាត អង្គការ Water.org សមាគម និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ដែលបានបន្តជួយគាំទ្រ និងចូលរួមយ៉ាងសកម្មក្នុងសិក្ខាសាលានាថ្ងៃនេះ ដើម្បីចូលរួមពង្រឹង ពង្រីក និងអភិវឌ្ឍវិស័យទឹកស្អាតនៅកម្ពុជា ស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា។

## ៣. សេចក្តីសន្និដ្ឋាន

សិក្ខាសាលាស្តីពី **«ការឆ្លុះបញ្ចាំង និងការឆ្លើយតបទៅនឹងអនុសាសន៍ណែនាំរបស់ក្រុមអធិការកិច្ច»** បានប្រព្រឹត្តទៅដោយជោគជ័យ និងសម្រេចបាននូវគោលបំណងដែលបានកំណត់។ តាមរយៈបទបង្ហាញ និងកិច្ចពិភាក្សា អ្នកចូលរួមបានយល់ដឹងកាន់តែច្បាស់អំពីលទ្ធផលនៃការចុះអធិការកិច្ច បញ្ហាប្រឈមក្នុងការអនុវត្តអនុសាសន៍ និងវិធានការកែលម្អដែលត្រូវអនុវត្ត ដើម្បីពង្រឹងការគ្រប់គ្រង និងលើកកម្ពស់គុណភាពសេវាផ្គត់ផ្គង់ទឹកស្អាត។ 

សិក្ខាសាលាក៏បានឆ្លុះបញ្ចាំងពីបញ្ហាប្រឈមរួមរបស់ប្រតិបត្តិករ ដូចជា ការពង្រីកតំបន់សេវាកម្ម ការគ្រប់គ្រងប្រតិបត្តិការ ការធានាប្រភពទឹក ការអនុលោមតាមអាជ្ញាបណ្ណ និងតម្រូវការគាំទ្រផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងគោលនយោបាយ។ ទន្ទឹមនឹងនេះ ក្រសួង ឧ.វ.ប.ន. សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា និងអង្គការ Water.org បានបញ្ជាក់ពីការបន្តសហការយ៉ាងជិតស្និទ្ធ ក្នុងការគាំទ្រប្រតិបត្តិករឱ្យអនុវត្តអនុសាសន៍ និងផែនការកែលម្អប្រកបដោយប្រសិទ្ធភាព។

ជារួម សិក្ខាសាលានេះបានបង្កើតវេទិកាសម្រាប់ការផ្លាស់ប្តូរបទពិសោធន៍ ការពង្រឹងកិច្ចសហការ និងការកំណត់ទិសដៅរួម ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងនិរន្តរភាពនៃសេវាផ្គត់ផ្គង់ទឹកស្អាត ស្របតាមច្បាប់ គោលនយោបាយរបស់រាជរដ្ឋាភិបាល និងគោលដៅអភិវឌ្ឍន៍វិស័យទឹកស្អាតនៅកម្ពុជា។

## ៤. ឧបសម្ព័ន្ធ

- **ឧបសម្ព័ន្ធទី ១៖** បញ្ជីអ្នកចូលរួម
- **ឧបសម្ព័ន្ធទី ២៖** កម្មវិធីនៃសិក្ខាសាលា
- **ឧបសម្ព័ន្ធទី ៣៖** បទបង្ហាញស្តីពី«លទ្ធផលនៃការវាយតម្លៃរបស់ក្រុមការងារចុះពិនិត្យ និងវាយតម្លៃស្ថានភាពជាក់ស្តែងរបស់ប្រតិបត្តិករផ្តល់សេវាផ្គង់ផ្គង់ទឹកស្អាតឯកជន និងចំណុចសំខាន់ៗរកឃើញ»
- **ឧបសម្ព័ន្ធទី ៤៖** បទបង្ហាញអំពី«លទ្ធផលនៃការស្ទង់មតិរបស់ប្រតិបត្តិករ»។

ថ្ងៃចន្ទ ៥រោច ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែសីហា ឆ្នាំ២០២៦
**អ្នកធ្វើរបាយការណ៍**

**លោកស្រី តូច សុគន្ធា**
**អ្នកសម្របសម្រួលកម្មវិធីជាន់ខ្ពស់**

**នាយកប្រតិបត្តិសមាគម**

**លោក លឹម មិញ**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សិក្ខាសាលាស្តីពី
# «ការផ្លាស់ប្តូរបញ្ហាប្រឈម និងការឆ្លើយតបទៅនឹងអនុសាសន៍ណែនាំរបស់ក្រុមអធិការកិច្ច»

## ១. គោលបំណង

១. កំណត់ចំណុចដែលប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ត្រូវកែលម្អ ដោយផ្អែកលើលទ្ធផលក្នុងរបាយការណ៍។

២. ពិភាក្សាអំពីវិធីសាស្ត្រ និងផែនការដែលប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននឹងអនុវត្ត ដើម្បីកែលម្អ ដោយផ្អែកលើលទ្ធផល និងអនុសាសន៍ក្នុងរបាយការណ៍។

៣. ពិភាក្សាអំពីការគាំទ្ររបស់ក្រសួង ឧ.វ.ប.ន. និង/ឬសមាគម ដៃគូអភិវឌ្ឍន៍ក្នុងការជួយប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនអនុវត្តសកម្មភាពកែលម្អទាំងនោះ។

## ២. កាលបរិច្ឆេទ និងទីកន្លែង

សិក្ខាសាលានេះនឹងរៀបចំឡើងរយៈពេលមួយថ្ងៃ គឺនៅ**ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៦** ចាប់ពីម៉ោង ០៨:០០ ព្រឹក រហូតដល់ម៉ោង ០៥:០០ ល្ងាច នៅ**សណ្ឋាគារ កាំបូឌីយ៉ាណា រាជធានីភ្នំពេញ**។

## ៣. សមាសភាពអ្នកចូលរួម

សមាសភាពអ្នកចូលរួមប្រមាណ **៨៥ នាក់** ដែលអញ្ជើញមកពី៖

- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ឧ.វ.ប.ន.) ៖ ៣ នាក់
- ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន (សមាជិកគម្រោង) ៖ ៧៤ នាក់
- អង្គការ Water.org ៖ ៣ នាក់
- សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ៖ ៥ នាក់

## ៤. របៀបវារៈ

| ម៉ោង | ប្រធានបទ | សម្របសម្រួលដោយ |
|---|---|---|
| ០៧.៣០-០៨.៣០ | ការចុះឈ្មោះ និងការណែនាំអំពីកម្មវិធី | ក្រុមការងារគម្រោង |
| **កម្មវិធីបើកសិក្ខាសាលា** | | |
| ០៨.៣០-០៨.៣៥ | ការប្រកាសហេតុ និងគោរពទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា | **លោកស្រី តូច សុគន្ធា**<br>អ្នកសម្របសម្រួលកម្មវិធីជាន់ខ្ពស់ |
| ០៨.៣៥-០៨.៤៥ | មតិស្វាគមន៍របស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា | **លោក លឹម មិញ**<br>នាយកប្រតិបត្តិសមាគម |
| ០៨.៤៥-០៩.១៥ | សុន្ទរកថាបើកសិក្ខាសាលា ដោយក្រសួង ឧ.វ.ប.ន | **ឯកឧត្តម អ៊ុំ សុថា**<br>រដ្ឋលេខាធិការក្រសួងឧ.វ.ប.ន. |
| ០៩.១៥-០៩.៣០ | ថតរូបអនុស្សាវរីយជាមួយគណៈអធិបតី | ក្រុមការងារ |
| **០៩.៣០-០៩.៤៥** | **សម្រាកអាហារសម្រន់** | |

| ម៉ោង | ប្រធានបទ | សម្របសម្រួលដោយ |
|---|---|---|
| ០៩.៤៥-១០.៤៥ | បង្ហាញលទ្ធផលវាយតម្លៃ (Assessment Findings) និងចំណុចសំខាន់ៗ<br>សំណួរ ចម្លើយ | តំណាងអគ្គនាយកដ្ឋានទឹកស្អាត ក្រសួង ឧ.វ.ប.ន. |
| ១០.៤៥-១២.០០ | **ពិភាក្សាក្រុមតូច**<br>១. យោងតាមរបាយការណ៍អធិការកិច្ចរបស់ក្រសួង ឧ.វ.ប.ន. តើអ្វីខ្លះជាចំណុចអាទិភាពសម្រាប់ការកែលម្អ ស្ថានីយរបស់អ្នក?<br>២. តើចំណុចអាទិភាពសម្រាប់កែលម្អណាខ្លះដែលស្ថានីយរបស់អ្នកអាចអនុវត្តបាន?<br>៣. តើចំណុចអាទិភាពណាខ្លះដែលមិនអាចអនុវត្តបាន? ហេតុអ្វី? | **លោក លឹម មិញ**<br>នាយកប្រតិបត្តិសមាគម |
| **១២.០០-១៣.៣០** | **សម្រាកអាហារថ្ងៃត្រង់** | |
| ១៣.៣០-១៤.៣០ | **ធ្វើការងារតាមស្ថានីយនីមួយៗ**<br>សូមស្ថានីយនីមួយៗធ្វើផែនការកែលម្អរបស់អ្នកដោយរួមបញ្ចូល<br>• សកម្មភាព<br>• អ្នកទទួលខុសត្រូវ<br>• ពេលវេលា<br>• ថវិកា | **លោកស្រី តូច សុគន្ធា**<br>អ្នកសម្របសម្រួលកម្មវិធីជាន់ខ្ពស់ |
| **១៥.០០-១៥.៣០** | **សម្រាកអាហារសម្រន់** | |
| ១៥.៣០-១៦.៣០ | **ពិភាក្សាក្រុមធំអំពី៖**<br>• ការគាំទ្រពី ក្រសួង ឧ.វ.ប.ន. សមាគម CWA និងគម្រោង ដើម្បីជួយអនុវត្តផែនការកែលម្អ (បច្ចេកទេស ការបណ្តុះបណ្តាល ការណែនាំ ការតាមដាន។ល។)<br>• កំណត់សកម្មភាពបន្ទាប់ និងកាលវិភាគតាមដាន | **លោក លឹម មិញ**<br>នាយកប្រតិបត្តិសមាគម |
| **កម្មវិធីបិទសិក្ខាសាលា** | | |
| ១៦.៣០-១៦.៤៥ | របាយការណ៍សង្ខេបស្តីពីលទ្ធផលនៃសិក្ខាសាលា | **លោក លឹម មិញ**<br>នាយកប្រតិបត្តិសមាគម |
| ១៦.៤៥-១៧.០០ | មតិសំណេះសំណាល អនុសាសន៍ផ្តាំផ្ញើ និងបិទសិក្ខាសាលា ដោយ ក្រសួង ឧ.វ.ប.ន. | **ឯកឧត្តម អ៊ុំ សុថា**<br>រដ្ឋលេខាធិការក្រសួង ឧ.វ.ប.ន. |

*សូមរក្សាសិទ្ធិកែប្រែក្នុងករណីចាំបាច់!*